**សកម្មភាព** ៖ **ល្បែងគប់ពណ៌**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ របស់ដែលអាចគប់បាន ដូចជាបាល់ និងក្រដាសពណ៌ទាំង៧ មានពណ៌ក្រហម ខៀវ លឿង បៃតង ទឹកក្រូច ស្វាយ ខៀវស្វាយ កាត់វាជារាងការេ ដើម្បីឱ្យក្មេងៗងាយស្រួលកាន់ និងមើល។

**ការរៀបចំ** ៖ ស្វែងរកបាល់ ឬរបស់ដែលអាចបោះបាន និងឱ្យក្មេងៗឈរជាក្រុម។ ធ្វើកាតពណ៌ឱ្យបានគ្រប់គ្រាន់សម្រាប់ក្មេងៗនីមួយៗទទួលបានកាតពណ៌គ្រប់ៗគ្នាទៅតាមអ្វីដែលអាចធ្វើទៅបាន។

**សេចក្ដីណែនាំ៖**

1. ចែកក្មេងៗជាក្រុម ពី១០-១៥នាក់។
2. ក្រុមនីមួយៗត្រូវអង្គុយជារង្វង់ បើបន្ទប់មានទំហំតូចត្រូវឱ្យក្មេងៗអង្គុយទល់មុខគ្នាក៏បានដែរ។
3. អ្នកគ្រូចែកកាតពណ៌ទៅក្មេងៗម្នាក់ ១សន្លឹកគ្រប់គ្នា។
4. ឱ្យក្មេងៗទុកកាតពណ៌នៅកន្លែងណាមួយដែលអ្នកផ្សេងមិនអាចមើលឃើញ។
5. អ្នកគ្រូត្រូវឱ្យបាល់ទៅក្មេងទី១។
6. ក្មេងទី ១បោះបាល់ទៅកាន់ក្មេងបន្ទាប់ ហើយនិយាយពណ៌ដែលខ្លួនឯងមាន។ ឧទាហរណ៍.ក្មេងនោះនិយាយថាពណ៌ក្រហមបន្ទាប់មកបោះបាល់ទៅក្មេងទី២ដែលមានកាន់កាតពណ៌ខៀវ។ ដូច្នេះក្មេងទី ២នោះនិយាយថា ពណ៌ក្រហម ពណ៌ខៀវ។
7. ក្មេងទី ៣និយាយពណ៌របស់ខ្លួនឯង ហើយនិយាយពណ៌របស់ក្មេងទី២ដែលបានបោះបាល់មក ឧទាហរណ៍. ពណ៌ខៀវ និងពណ៌បៃតង (ពណ៌ខៀវរបស់ក្មេងទី២ ពណ៌បៃតងជារបស់ក្មេងទី៣ )
8. អ្នកគ្រូធ្វើបែបនេះដដែលៗរហូតដល់ល្បែងនេះត្រូវបានបញ្ចប់ និងក្មេងបានចូលរួមទាំងអស់ ។

**ការប្រែប្រួល៖**

ល្បែនេះអ្នកអាចលេងជាមួយពាក្យផ្សេងៗទៀតបាន សត្វ លេខ ផ្លែឈើ បន្លែ និងឧបករណ៍តន្ត្រី...។ ល្បែងនេះមិនមែនសម្រាប់លេងតែជាមួយកាតពណ៌ និងមិនត្រូវប្រាប់ក្មេងមុនពេលចាប់ផ្ដើមឡើយ។

នៅក្នុងកំណែនេះ ក្មេងទី១ សម្រេចចិត្តជ្រើសរើសពណ៌មួយណាដែលត្រូវនិយាយមុនគេ ហើយនិយាយថាពណ៌នៅពេលបោះបាល់ទៅកូន២។
ល្បែងនៅតែបន្តដូចនេះដោយក្មេងៗនិយាយម្តងទៀតនូវពណ៌ដែលពួកគេទើបតែលឺ និងបន្ថែមពណ៌ផ្សេងនៅពេលពួកគេបោះ។